00352318

ឯកសារ/Nº D97/9/2

**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស |
| **ថ្ងៃដាក់** | : | ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ |
| **ភាគីអ្នកដាក់** | : | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |
| **ប្រភេទឯកសារដែលស្នើឡើង** | : | **សាធារណៈ** |

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅនឹងសំណើរបស់ អៀង សារី សុំឲ្យដាក់ទណ្ឌកម្ម ប្រឆាំងនឹងសហព្រះរាជអាជ្ញា ដោយចោទប្រកាន់ថាបានបំពានតុលាការ ទាក់ទិននឹងច្បាប់ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម

---

**អ្នកដាក់ឯកសារ:**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉ែត ចរិយា

លោក William SMITH

លោក តាន់ សេណារ៉ុង

លោក Anees AHMED

**អ្នកទទួលឯកសារ:**

**ការិ.សហចៅក្រមស៊ើបអង្កេត៖**

លោក យូ ប៊ុនឡេង

លោក Marcel LEMONDE

**មេធាវីការពារក្តីរបស់ជនត្រូវចោទ/ដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ អៀង សារី៖**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 16 / JUL / 2009
ម៉ោង (Time/Heure): 11:05
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 17 / 07 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

00352319

ឯកសារៈ D97/9/2

*សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស*

## ១. ចម្លើយតប

១. ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី បានដាក់សំណើមួយ ("ពាក្យសុំ") ជូនទៅសហចៅក្រមស៊ើបអង្កេតសុំឱ្យដាក់ទណ្ឌកម្មសហព្រះរាជអាជ្ញា ដោយបានចោទថាបានបំភាន់សហចៅក្រមស៊ើបអង្កេត ក្នុងការដែលមិនបានបង្ហាញច្បាប់ឱ្យបានត្រឹមត្រូវ នៅក្នុងសេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ("សេចក្តីសង្កេតបន្ថែម" និង "សហកម្មឧក្រិដ្ឋកម្មរួម")[1] ។ ដើមបណ្តឹងឧទ្ធរណ៍បានចោទប្រកាន់ថា ការដែលមិនបានលើកយោងនូវដំណោះស្រាយណាមួយរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ("ដំណោះស្រាយរបស់មហាសន្និបាត អ.ស.ប") ដែលធ្វើខូចដល់ករណីរបស់សហព្រះរាជអាជ្ញា ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម សហព្រះរាជអាជ្ញា បាន "រួមគំនិតគ្នាដោយមិនពិចារណាវែងឆ្ងាយ ក្នុងចេតនាដើម្បីបំភាន់ និងបញ្ឆោត" ឱ្យសហចៅក្រមស៊ើបអង្កេតយល់ខុស[2] ។

២. សហព្រះរាជអាជ្ញា សូមស្នើដល់សហចៅក្រមស៊ើបអង្កេត ឱ្យច្រានចោលពាក្យសុំនេះ ។

៣. សហព្រះរាជអាជ្ញាសូមថ្លែងថា សេចក្តីសង្កេតបន្ថែមបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវតាមការយល់ដឹងរបស់ខ្លួន អំពីច្បាប់អ.វ.ត.ក ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម នៅថ្ងៃដាក់សេចក្តីសង្កេតនោះ ។ ខណៈដែលគ្មានសេចក្តីថ្លែងសំអាងខាងផ្លូវច្បាប់ អាចទាមទារឱ្យមានការយោងទៅរាល់ប្រភពច្បាប់ទាំងអស់ដែលអាចរកបានស្តីពីបញ្ហានេះ ចំពោះចំណេះដឹង និងជំនឿរបស់សហព្រះរាជអាជ្ញាវិញ សេចក្តីសង្កេតបន្ថែមដែលមានការត្រួតពិនិត្យយ៉ាងទូលំទូលាយ អំពីប្រភពច្បាប់នានា ដើម្បីជាការគាំទ្រដល់ការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលថា សហ

---

1 *ករណីរបស់ អៀងសារី,* សេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨, D97/8 ។

2 *ករណីរបស់ អៀងសារី,* សំណើរបស់ អៀង សារី សុំឱ្យដាក់ទណ្ឌកម្មតាមវិធានផ្ទៃក្នុង៣៥ ដោយសារសហព្រះរាជអាជ្ញា បានបំភ័ន្តតុលាការនៅក្នុងការដាក់សេចក្តីសង្កេតបន្ថែមស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ដែលបានដាក់ធ្វើនៅថ្ងៃទី៣១ ធ្នូ ២០០៨, ចុះថ្ងៃទី២៩ មិថុនា ឆ្នាំ២០០៩, D97/9, កថាខ័ណ្ឌទី ៧ [*ចាប់ពីនេះតទៅហៅថា* ពាក្យសុំ] ។

00352320





កម្មខក្រិដ្ឋកម្មរួម គឺជាផ្នែកនៃទម្លាប់អន្តរជាតិក្នុងអម្លុងឆ្នាំ១៩៧៥-១៩៧៩ និងថាបើដូច្នេះ អាចអនុវត្តបាននៅចំពោះមុខតុលាការនេះ ។

៤. ទាំងសហព្រះរាជអាជ្ញាខ្លួនឯងផ្ទាល់ ឬទាំងចំណេះដឹងរបស់ខ្លួនទៅលើបុគ្គលិករបស់សហព្រះរាជអាជ្ញាណាម្នាក់ គឺមិនដែលបានដកហូតទុកដោយគិតទុកជាមុន ឬបានឱ្យយោបល់ឱ្យជនណាម្នាក់ផ្សេងឱ្យដកហូតទុក នូវប្រភពច្បាប់ពាក់ព័ន្ធណាមួយដែលគេបានស្គាល់ ពីការមិនឱ្យដាក់ចូលទៅក្នុងការដាក់ឯកសារណាមួយ នៅចំពោះមុខអង្គតុលាការណាមួយនៃតុលាការនេះទេ ។ ការចោទប្រកាន់ដូចដែលបានពោលដោយសង្ខេបនេះ ដែលមាននៅក្នុងពាក្យសុំ គឺគ្មានមូលដ្ឋានទេ អាស្រ័យហេតុនេះគួរតែមិនត្រូវបានអើពើ និង/ឬ គួរតែបានច្រានចោល ។

៥. បើសិន ដើមបណ្តឹងឧទ្ធរណ៍មានការសោយសោកក្នុងចិត្តដែលថា សហព្រះរាជអាជ្ញាមិនបានដាក់ឯកសារមួយ ដែលអាចធ្វើឱ្យខូចដល់ករណីរបស់សហព្រះរាជអាជ្ញា នោះវាជាការបើកចំហរដល់ដើមបណ្តឹងឧទ្ធរណ៍ ដើម្បីនាំយកឯកសារនោះជាចំណាប់អារម្មណ៍របស់សហចៅក្រមស៊ើបអង្កេត ដើម្បីជួយពួកគេក្នុងការកំណត់សម្រេចមួយប្រកបដោយយុត្តិធម៌ លើបញ្ហានៃការអនុវត្តន៍សហកម្មខក្រិដ្ឋកម្មរួមនេះ ។ ធ្វើដូច្នេះ ទើបជាធម្មជាតិនៃកិច្ចដំណើរការនីតិវិធីដេញដោលដែលបានធានាដោយតុលាការនេះតាមវិធាន២១.១.ក នៃវិធានផ្ទៃក្នុង (“វិធាន”) ។ សហចៅក្រមស៊ើបអង្កេតមិនទាន់ធ្វើការសម្រេចលើបញ្ហាសហកម្មខក្រិដ្ឋកម្មរួមនេះនៅឡើយទេ ។ នៅក្នុងការសម្រេចចំពោះបញ្ហានេះ គឺវាច្បាស់លាស់ថា សហចៅក្រមស៊ើបអង្កេតត្រូវពិចារណាទៅលើឯកសារណាក៏ដោយដែលបាននាំយកមក ដោយដើមបណ្តឹងឧទ្ធរណ៍ ដែលផ្ទុយពីករណីរបស់សហព្រះរាជអាជ្ញា ។ ប៉ុន្តែអ្វីដែលដើមបណ្តឹងឧទ្ធរណ៍មិនអាចធ្វើបាន- ដូចអ្វីដែលគាត់បានស្វែងរកនៅក្នុងពាក្យសុំរបស់ខ្លួននេះដែរ- គឺការបង្ខំសហព្រះរាជអាជ្ញាឱ្យដាក់ឯកសារមួយ តាមសេចក្តីថ្លែងសំអាងរបស់ខ្លួន (របស់សហព្រះរាជអាជ្ញា)[3] ។

[3] ពាក្យសុំ, គ្រង់សំណូមពរ (ក) ។

00352321





៦. សហព្រះរាជអាជ្ញា បានតាមដានទៅលើ ដំណោះស្រាយរបស់មហាសន្និបាត អ.ស.ប និងថា បើយោងតាមសហព្រះរាជអាជ្ញា វា (ដំណោះស្រាយរបស់មហាសន្និបាត អ.ស.ប) ផ្ទុយគ្នាទៅនឹងការសន្និដ្ឋានរបស់ដើមបណ្តឹងឧទ្ធរណ៍ មិនធ្វើឱ្យខូចដល់សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលថា សហកម្មឧក្រិដ្ឋកម្មរួម គឺជាផ្នែកនៃទម្លាប់អន្តរជាតិ ក្នុងអម្លុងឆ្នាំ១៩៧៥-១៩៧៩ ទេ[4] ។

៧. សហព្រះរាជអាជ្ញាសន្និដ្ឋានថា មូលដ្ឋានផ្នែកអង្គហេតុនៃពាក្យសុំ - ដែលមានតែ "ការប្រមូលចងក្រងឡើងវិញដែលមានការចូលរួមចំណែក"[5] ដែលគ្មានមូលដ្ឋានរបស់ក្រុមប្រឹក្សារបស់មេធាវីការពារក្តី និងភាគីទីបី - មិនអាចមានទម្ងន់ស្មើនឹងអំពើណាមួយដែលអាចជឿទុកចិត្តបាននាំដាក់ការដាក់ទណ្ឌកម្មក្រោមវិធាន ៣៥.១ នៃវិធានផ្ទៃក្នុង សម្រាប់ការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលយុត្តិធម៌ បានទេ ។ ជាការបន្ថែម អង្គហេតុទាំងនេះ ទោះបីគេជឿថាវាពិតក៏ដោយ ក៏មិនគ្រប់គ្រាន់ឱ្យស្នើសុំឱ្យមានការដាក់ទណ្ឌកម្មបានដែរ ។ ការដែលមិនបានដាក់ដំណោះស្រាយរបស់មហាសន្និបាត អ.ស.ប ដែលគេអាចរកបានជាសាធារណៈ ដែលភាគីណាក៏ដោយអាចដាក់បណ្តឹងវិវាទមួយ ដែលមិនទាន់បានមានការសម្រេចជាស្ថាពរនៅឡើយដោយសហចៅក្រមស៊ើបអង្កេត មិនធ្វើឱ្យអង្គហេតុដែលមិនគ្រប់គ្រាន់នោះក្រោកឈរឡើងដើម្បីយកមកធ្វើការដាក់ទណ្ឌកម្មបានឡើយ ។ សម្រាប់ការដាក់ទណ្ឌកម្មប្រដៅតាមវិធាន ៣៥.១ ធ្វើទៅបាន (១) លុះត្រាមានជនណាម្នាក់ជ្រៀតជ្រែកនៅក្នុងកិច្ចការរដ្ឋបាល, (២) ត្រូវតែមានការជៀតជ្រែកពិតប្រាកដ និង (៣) ការជៀតជ្រែកនេះត្រូវតែបានធ្វើឡើងដោយដឹងខ្លួនជាមុន និង ដោយមានចេតនា ។ ពាក្យសុំ ខកខានមិនបានបំពេញឱ្យបានគ្រប់ចំណុចទាំងបីនេះទេ ។

## ២. សេចក្តីសន្និដ្ឋាន

---

[4] ពាក្យសុំ, ត្រង់កថាខ័ណ្ឌទី ៦ ។

[5] ពាក្យសុំ, ត្រង់កំណត់សំគាល់ចុងទំព័រទី៣ ។

00352322

ឯកសារ/ល.D 96/1/2

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ចៅ.ស*

៨. ហេតុដូច្នេះហើយ សហព្រះរាជអាជ្ញា សូមស្នើឱ្យសហចៅក្រមស៊ើបអង្កេត ច្រានចោលយ៉ាងសង្ខេបនូវពាក្យសុំនេះ ៕

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង** **លោក** Robert PETIT